# COVID-19 Report from RHCP

## Situation Report (as of June 5th, 2020)

Olmsted County: 689 cases
Minnesota: 26,980 cases
United States: 1,862,656 cases
(Reference: MN Department of Health, CDC)

## បញ្ឈប់ការរាលដាល

ប្រើក្រណាត់រុំមខពេលនៅកន្លែងសាធារណៈ
យកដៃបទមាត់ពេលក្អកឬកណ្ដាស់។
លាងដៃជាមួយសាប៊ូនិងទឹកឬប្រើអាលកុលលាងដៃអោយបានញឹកញាប់។
ត្រូវនៅអោយឆ្ងាយពីគ្នា - នៅអោយឆ្ងាយ៦ហ្វីត។
ត្រូវនៅផ្ទះហើយនៅដាច់ដោយឡែកពីគេ បើអ្នកមិនស្រួលខ្លួន។
ត្រូវទៅធ្វើតេស្តមើល COVID-19 បើអ្នកមិនស្រួលខ្លួន។

## សំណួររបស់អ្នកដែលបានឆ្លើយហើយ

1. នាយកដ្ឋានសុខាភិបាលរបស់Minnesotaមានអនុសាសន៍ថ្មីអ្វីទៅចំពោះការធ្វើតេស្តCOVID-19?
នៅខែមិថុនា ថ្ងៃទី២, ២០២០, នាយកដ្ឋានសុខាភិបាលរបស់ Minnesota (MDH) បានចេញប្រេក្សាសុខភាពថ្មីមួយទាក់ទងទៅការធ្វើតេស្តCOVID-19 ដោយមានមនុស្សច្រើនអ្នក។ MDH កំពុងផ្ដល់អនុសាសន៍ឱ្យពង្រីកការធ្វើតេស្តCOVID-19ដោយសារព្រឹក្តការណ៍ថ្មីៗ, ភាពវឹកវរស៊ីវិលហើយនិងការឆ្លើយតបទៅភាពវឹកវរស៊ីវិលដែលបានកើតឡើងទូទាំងរដ្ឋចាប់ផ្តើមនៅថ្ងៃទី២៥ ឧសភា ២០២០ នេះ។

ឥឡូវនេះ
MDHសូមផ្តល់អនុសាសន៍ឱ្យធ្វើតេស្តសម្រាប់ក្រុមមនុស្សខាងក្រោមនេះទោះបើពួកគេមានរោគសញ្ញាឬអត់៖

- អ្នកដែលចូលរួមក្នុងវិស័យការតវ៉ាក្នុងសង្គមឬព្រឹត្តិការណ៍ដែលពាក់ព័ន្ធនោះ,
- មនុស្សដែលបានចូលរួមក្នុងការជួបជុំធំៗ ដូចជាការតវ៉ា ការសម្អាតសហគមន៍និងកិច្ចប្រឹងប្រែងស្តារ ការប្រុងប្រយ័ត្ន ការប្រជុំអ្នកការពារសង្កាត់ អ្នកជំនួយក្នុងគ្រាអាសន្ននិងអ្នកផ្សេងទៀតដែលបាមជួយនឹង ព្រឹត្តិការណ៍ផ្សេងៗទៀត។

2. ហែតអ្វីមានជាមានអនុសាសន៍ថ្មីទាក់ទងនឹងការធ្វើតេស្ត?
មនុស្សរាប់ពាន់អ្នកប្រហែលជាត្រូវបានប៉ះពាល់នឹងCOVID-19ដោយសារតែមានមនុស្សច្រើនពេកនៅមួយកន្លែង។ ជាប្រការសំខាន់ណាស់បើបានកំណត់អត្តសញ្ញាណនិងធ្វើតេស្តបុគ្គលដែលអាចចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈធំ; ¡វានឹងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពក្នុងការកំណត់ការណនិងដង្កើតភាពនៅដាច់ដោយឡែកនិងវិធានការដាច់ដោយឡែកពីគ្នា

3. តើអ្នកណាដែលត្រូវមានធ្វើតេស្តជាក់លាក់សម្រាប់ការឆ្លងមេរោគCOVID-19?

- អ្នកដែលបានចូលរួមធ្វើបាត់កម្មក្នុងសង្គមឬការជួបជុំធំៗ
- អ្នកដែលមានរោគសញ្ញាCOVID-19
- អ្នកដែលនៅកន្លែងប្រមូលផ្តុំដូចជាកន្លែងថែទាំរយៈពេលវែង ទីជម្រកនិងពន្ធនាគារ
- បុគ្គលិកធ្វើការនៅកន្លែងដែលមានហសនិភ័យខ្ពស់ដូចជានៅមន្ទីពេទ្យនិងគ្លីនិក
- ការសើបអង្កេតជាក្រុមដែលមានមនុស្សជាក្រុមៗមានការពាក់ព័ន្ធជាមួយករណីCOVID-19
- អ្នកជំងឺដែលអត់មានរោគសញ្ញាតែត្រូវធ្វើនីតិវិធីវេជ្ជសាស្រ្តណាមួយឬត្រូវចូលស្នាក់នៅក្នុងមន្ទីពេទ្យ

- កម្មករសំខាន់ដែលអត់មានរោគសញ្ញាដូចជាកម្មករធ្វើទឹកភ្លើង, បុគ្គលិកពេទ្យ, អ្នកជំនួយគ្រាអាសន្ន, ផ្ទាំជាតិ, អ្នកបើកឡានក្រុង, ទីផ្សារ, កន្លែងធ្វើអាហារ, រោងចក្រនិងកន្លែងចែកចាយគ្រឿងពេទ្យនិងធនធានសំខាន់និងបុគ្គលិករដ្ឋាភិបាល

កន្លែងធ្វើតេស្ត COVID-19នៅម៉េយ៉ូគ្លីនិកNorthwest
4111 US-52 North
ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ, 9:30 am to 5:00 pm
ថ្ងៃសៅរ៍និងថ្ងៃអាទិត្យ, 10:00 am to 4:00 pm

អ្នក ជាអ្នកនៅក្នុងសហគមន៍ គឺជាអ្នកនៅជួរមុខដើម្បីបញ្ឈប់COVID-19។
ដោយការលាងដៃ សំអាតនិងធ្វើអនាម័យ។ ដោយនៅឆ្ងាយពីគ្នា។ ដោយត្រូវនៅផ្ទះ។
**យើងទាំងអស់គ្នានៅរួមជាមួយគ្នា។ យើងនិងបានជាសះស្បើយជាមួយគ្នា។**